**គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បី**
**បង្កើន ផលិតភាពជុំវិញតំបន់ទន្លេសាប**

# *បច្ចេកទេសបណ្តុះផ្សិតចំបើងតាមបែបចំហុយ*TSTD





*វដ្តជីវិតលូតលាស់របស់ផ្សិតចំបើង*

## ក-សេចក្តីផ្តើម

ការបណ្តុះផ្សិតចំបើង ផ្តល់ប្រភពចំណូលថ្មីជាប្រចាំ ដល់គ្រួសារដោយគ្រាន់តែចំណាយពេលទំនេរ និង ធនធានមានមួយចំនួនប៉ុណ្ណោះ ។ ទន្ទឹមនឹងការបណ្តុះផ្សិតកសិករអាចប្រកបមុខរបរ ឬការងារផ្សេងទៀតបាន ។ តាមបទពិសោធន៍បអនុវត្តកន្លងមកកសិករគ្រួសារមធ្យម មានគ្នា ៤នាក់ អាចរកប្រាក់ចំណូលបន្ថែមពីការបណ្តុះ ផ្សិតមួយរោង (ប្រហែល ១០០ ដុំកំប៉ុស្តិ៍) បានប្រមាណពី ២០ ទៅ ២៥ ម៉ឺនរៀល ក្នុង១សារ រយៈពេល ១ខែ ។ ប្រាក់ចំណូលនេះ នឹងកើនថែមទៀត ទៅតាមចំនួនដុំ និងការបណ្តុះផ្សិតច្រើនរោង។

## ខ-វិធីបណ្តុះផ្សិតចំបើងនៅកម្ពុជា

នៅកម្ពុជា ការបណ្តុះផ្សិតចំបើង ធ្វើតាម ២ របៀប គឺ ៖
(១) ប្រើចំបើងដុតជារង ឬ ថ្នាលរួចហើយគ្របហាលថ្ងៃ
(២) ប្រើល្បាយចំហុយ និង ផ្អាប់ក្នុងរោងហប់បិទជិត។

ក្នុងឯកសារណែនាំបច្ចេកទេសសម្រាប់កសិករនេះ យើងនឹងលើកយកមកបង្ហាញតែរបៀបទី ២ ប៉ុណ្ណោះ។ របៀប ទី២ នេះ អាចប្រើបណ្តុះផ្សិត បានពេញមួយឆ្នាំ ទោះបីជា រដូវវស្សា មានភ្លៀងជោគជាំ ក៏ដោយ។

## គ-លក្ខណៈ និង តម្រូវការលូតលាស់ផ្សិតចំបើង

ផ្សិតចំបើងត្រូវការលក្ខខណ្ឌអាកាសធាតុក្តៅ ហើយសើមសម្រាប់ការលូតលាស់របស់វា ។ កំដៅកើតមកពីកំប៉ុស្តិ៍កម្មរបស់ដុំល្បាយបណ្តុះ ជាមួយនឹងសំណើមសមស្រប ក្នុងកន្លែងហប់ ដែលផុតពីកំដៅ និង ពន្លឺថ្ងៃផ្ទាល់ខ្លាំង ។ ផ្សិតអាចលូតលាស់បានល្អ ដោយស្រូបយកសារធាតុចិញ្ចឹមពីល្បាយកំប៉ុស្តិ៍បណ្តុះ ដាក់ក្នុងកន្លែងមានកំដៅសមស្រប (ពី ៣៥ ទៅ ៣៨ អង្សារ)។

## ឃ-ជំហ៊ាន និងដំណើរការរៀបចំបណ្តុះផ្សិតចំបើង

ការបណ្តុះផ្សិតចំបើងបែបចំហុយនេះ មាន៦ ជំហ៊ាន គឺ៖

### *១.ការលាយល្បាយ និង រៀបចំដុំល្បាយកំប៉ុស្តិ៍*





វត្ថុធាតុដើម សម្រាប់ផ្សំលាយធ្វើល្បាយកំប៉ុស្តិ៍បណ្តុះផ្សិតចំបើង រួមមាន៖

ក-ចំបើង ឬ គល់កញ្ច្រាំង ១០០គីឡូក្រាម *(បើមាន លាយជាមួយ កំប្លោកក្រៀម កាកអំពៅ ដើមចេកហាន់ហាលក្រៀម សំបកដំឡូងមី សំបកសណ្តែកបាយ ស្មូលគ ឬ កំទេចស្នូលពោត សរុបទាំងអស់ឲ្យបាន ១០០គីឡូ)។*

ខ-កន្ទក់ម៉ដ្ត ចំនួនពី ៨ ទៅ ១០គីឡូក្រាម
គ-ចុងអង្ករ (ឬ ម្សៅដំណើប ឬ ម្សៅពោត) ចំនួន ១គីឡូក្រាម
ឃ-កំបោរស ចំនួន០,៥ គីឡូក្រាម
ង-ជីអ៊ុយរ៉េ ចំនួន ០,៥ គីឡូក្រាម (លាយទឹកស្រោចលើល្បាយ) ឬ ជីលាមកសត្វកំប៉ុស្តិ៍ក្រៀម ពី ៥ ទៅ ១០គីឡូក្រាម។
ច-ទឹកស្អាតលាយល្បាយ (សំណើមពី ៦០ ទៅ ៧០%)។

ក្នុងការលាយល្បាយ ជាការល្អ ត្រូវលាយវត្ថុធាតុដើម (ក) (ឃ) និង (ច) ចូលគ្នាឱ្យសព្វល្អជាមុន រួចគ្របផ្អាប់ចោល រយៈពេល ពី ៥ ទៅ ៧ថ្ងៃ ទើបយកទៅលាយច្របល់គ្នានឹងវត្ថុធាតុដើមផ្សេងទៀត ឱ្យបានសព្វល្អសើមល្មម ។ សំណើមល្មមសមស្រប អាចកត់សំគាល់បាន តាមការយកល្បាយចំបើងលាយរួច មកពូត ឬ មួលមើលឱ្យមានលក្ខណៈ សើមជោគ តែមិនមានស្រក់ទឹកចុះ ។ ល្បាយលាយរួចនេះ ត្រូវគ្របផ្អាប់ទុក ពី ១២ ទៅ ២៤ម៉ោង ដើម្បីឱ្យវាទន់ចូលជាតិគ្នាល្អ មុននឹងយកទៅជាន់ពុម្ព និង ច្រកថង់ដាក់ចំហុយ (ឬ រៀបដាក់ផ្ទើរ ក្នុងរោងបាញ់ចំហាយទឹកចូល)។

### *២.ការចំហុយដុំល្បាយកំប៉ុស្តិ៍ បណ្ដុះផ្សិតចំបើង*



ដុំល្បាយ ចាំបាច់ត្រូវចំហុយ ឲ្យបានឆ្អិនល្អ (ឱ្យពុះជាប់ ពី ៣ ទៅ ៤ ម៉ោង) ដើម្បីកុំឱ្យដុះផ្សិតអាចម៍គោ។ ដើម្បីចំហុយបានដុំឆ្អិនល្អ និងសន្សំសំចៃអុស អ្នកបណ្ដុះផ្សិត ត្រូវរៀបចំចង្ក្រានគុកប្រើអង្កាម។ បន្ទាប់ពីចំហុយបានឆ្អិនសព្វល្អហើយ ស្រង់ដុំល្បាយ ទុកសំងិលឱ្យត្រជាក់ (ប្រហែលពី ៦ ទៅ ៨ ម៉ោង)។

### *៣.ការបញ្ចូលមេផ្សិតក្នុងថង់កំប៉ុស្តិ៍ បណ្ដុះ*

ប្រើមេផ្សិត មានគុណភាពល្អ សម្រាប់បណ្ដុះផ្សិត ។ ជ្រើសរើសកន្លែងស្អាត បិទជិត គ្មានខ្យល់បក់ សម្រាប់បញ្ចូលមេផ្សិត ។ អ្នកបញ្ចូលមេផ្សិត ត្រូវសំអាតដៃ និង សំភារៈ ជាមួយនឹងអាល់កុល ។ ស្រាយមាត់ថង់ដុំល្បាយម្ដងម្ដងៗ ដើម្បីដាក់បញ្ចូល មេផ្សិត ។ បន្ទាប់ពីបញ្ចូលមេផ្សិតរួច ដាក់កងទុយោទីបជ័រ រួចគ្របក្រដាស មុននឹងចងមាត់ថង់នឹងកៅស៊ូកង។



### *៤.ការបន្ទុំដុំល្បាយកំប៉ុស្តិ៍ បណ្ដុះ*

ការបន្ទុំដុំល្បាយ ត្រូវការកន្លែងបិទបាំងជិត មិនមានខ្យល់ចេញចូល និង មានកំដៅខ្លាំងជុល ។ យកតង់កៅស៊ូ មកក្រាល បន្ទាប់មក យកដុំល្បាយ ដែលបញ្ចូលមេរួច មកតំរៀបទល់មុខគ្នាជាជួរ ហើយគរលើគ្នា (រាង ជាសាជី) ។ រួចហើយ បត់ជាយតង់កៅស៊ូខ្ទប់រុំ ដូចជាក្បួយ ។ តាមដានកំដៅដុំល្បាយ ធ្វើ យ៉ាងណាឲ្យដុំល្បាយហាប់ ក្ដៅងំល្អ ហើយត្រឡប់បង្វិលថង់ល្បាយ នៅថ្ងៃទី ៦ បន្ទាប់ពីដាក់បន្ទុំ ។ ការបន្ទុំអាច ត្រូវការពេល ពី ៨ ទៅ ១២ ថ្ងៃ ទើបសរសៃរមេផ្សិតដើរសព្វជុំវិញផ្ទៃដុំល្បាយបានល្អ។



### *៥.ការព្យួរ និង ថែទាំដុំល្បាយ កំប៉ុស្ត ក្នុងរោងបណ្ដុះ*

ពេលដែលសរសៃរមេផ្សិត ដើរសព្វជុំវិញផ្ទៃដុំល្បាយបានល្អហើយ ត្រូវស្រាយលាថង់ស្រោបពីខាងក្រៅដុំល្បាយចេញ ហើយស្រោចទឹកលើដុំល្បាយ ឱ្យបានជោគសព្វល្អ (ស្រោចផ្ដាច់សសៃពីងពាង) ។ បន្ទាប់មក ចូកខ្សែដុំល្បាយនឹងទំពក់ដែក រួចហើយ ព្យួរដុំល្បាយ នឹងស្នួរឬស្សី ម្ដងមួយៗ កុំឱ្យប៉ះគ្នា ក្នុងរោងបណ្ដុះ ។ បន្ទាប់ពីព្យួររួច ត្រូវបិទរោងបណ្ដុះ ឱ្យជិត ហើយ សង្កត់ជើងថង់ជាជញ្ជាំង ឱ្យជិតជាប់ដី ។ ពិនិត្យតាមដានកំដៅ និង សំណើមរោងបណ្ដុះ។ បើឃើញដុំណាមួយស្ងួតពេក ត្រូវបាញ់ផ្សើម ដោយចំហាយទឹក (ឬ ដីកំប៉ុស្តិ៍រាវ ឬ ទឹកស្អាត) ។ ចំពោះដុំស្ងួត ដែលមាន ដុះពកចេញកូនផ្សិតហើយ ហាមបាញ់ទឹកចំលើដុំ *តែត្រូវបាញ់ទឹកផ្សើមដី នៅចំពីក្រោម ឬ ក្បែរដុំព្យួរស្ងួតនោះ ដើម្បីឱ្យហួត សំណើមទៅដុំនោះ* ។ ត្រូវរក្សាកំដៅក្នុងរោងបណ្ដុះ ឱ្យបានសមស្របជានិច្ច (ពី ៣៥ ទៅ ៣៨ អង្សារ)។ បើក្ដៅពេក ត្រូវបើកបង្អើបថង់ជើងជញ្ជាំងរោង ឱ្យកំដៅចេញខ្លះ តែបើត្រជាក់ពេក ត្រូវបើកគម្របរោង ឱ្យត្រូវពន្លឺថ្ងៃ ឬ បិទហ៊ុំរោងបន្ថែម កុំឱ្យប៉ះខ្យល់ត្រជាក់ខាងក្រៅ។





### *៦.ការប្រមូលផល និង ការថែទាំបន្ត*

ក្រោយពេលព្យួរពី ៨ ទៅ១០ថ្ងៃ ផ្សិតចាប់ផ្ដើមដុះ។ គេត្រូវបេះផ្សិតពីព្រលឹម ដោយកាត់យកកញ្ចុំណា ដែលមានផ្សិតធំល្មមលក់ ។ ចំពោះផ្សិតដុះជាកញ្ចុំ គេត្រូវប្រឡេះយកផ្សិតធំៗ ចំនួន៣សារ (ថ្ងៃ) ដោយឆ្កឹះចៀមៗ ។ យកកញ្ចុំផ្សិត ដែលមានផ្សិតធំៗ នៅថ្ងៃទី១ និង ថ្ងៃទី២ តែនៅថ្ងៃទី៣ ត្រូវឆ្កឹះដកយកទាំងធំ ទាំងតូច ។ បន្ទាប់មក ត្រូវបាញ់ផ្សើមទឹកដីកំប៉ុស្តិ៍ លើដុំល្បាយ ដែលបេះអស់និមួយៗ ហើយបន្តថែទាំកំដៅ និងសំណើម។ តាមធម្មតាក្នុង១ សារ (១ វដ្តជីវិតផ្សិត) មានរយៈពេលសរុបពី ៣០ ទៅ ៤៥ ថ្ងៃ គេអាចបេះផ្សិតបានពី ៥ខាំ ទៅ ១គីឡូ ពីដុំល្បាយនិមួយៗ ។







### ង-ការរៀបចំរោងបណ្ដុះផ្សិត

រោងបណ្ដុះផ្សិត ជារោងរក្សាកំដៅ បានមកពីកំប៉ុស្តិ៍កម្មល្បាយដុំ បណ្ដុះ ។ រោងនេះធ្វើពីបង្គោលឈើ ឬ ឬស្សី និងរនាបឬស្សី សម្រាប់ធ្វើបង្កាង ដំបូល ដូចដំបូលទូកនេសាទ ។ ដំបូល និង ជញ្ជាំងរោង ធ្វើពីថង់កៅស៊ូប្លាស្ទិច។ ដើម្បីរក្សាកំដៅបានល្អ គេអាចសង់រោង នេះ មានទទឹងពី ៣ ទៅ ៤ ម៉ែត្រ បណ្ដោយពី ៥ ទៅ ៦ម៉ែត្រ និង កំពស់ពី ១,៥ ទៅ ១,៧ម៉ែត្រ។ រោងបណ្ដុះត្រូវគ្របការពារកំដៅ និងភ្លៀង ដោយរោងប្រក់ស្លឹកពីលើមួយទៀត។





### ច-ទំនាក់ទំនងទិញមេផ្សិត:

មេផ្សិតចំបើង អាចទាក់ទងទិញ បានតាមអាសយដ្ឋាន៖

-*ក្រុងស្ទឹងសែន*: *សៀង សោភា* (០១១ ៧៩៦-១៦៤)

-*ស្រុកស្ទោង*: *គឹង សុរិន* (០១២ ៦៦២-៣៦៧)

-*ស្រុកព្រៃឈរ*: *ធឹង ប៊ុនធឿន* (០៩៩ ៦៧៣- ៨៨៣)

-*ស្រុកពួក*: *ភរ សុថន* (០៩២ ១៩០-៥៧៣)

*រៀបចំដោយ:* *លោក លីវ លាងហ៊ី*

livleanghy@gmail.com

*ព័ត៌មានបច្ចេកទេសផ្សេងទៀត*: www.telecentercambodia.org/